CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មាន

# BI-WEEKLY BULLETIN

លេខទី៤៨ ឆ្នាំ២០២១ (ថ្ងៃទី១៧ ដល់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២១)

CRF2021/048 (17 to 30 May 2021)

## ព័ត៌មានអំពីវិស័យស្រូវអង្ករ *(Rice News Briefing)*

## ក្នុងប្រទេស (In Cambodia)



### ការនាំចេញអង្ករបស់កម្ពុជាស្ថិតក្នុងភាពហានិភ័យ ដោយសារបញ្ហាកង្វះកុងតែន័រ និងការឡើងថ្លៃការដឹកជញ្ជូនតាមកប៉ាល់ខ្ពស់ដល់ទៅ៥ដង

**Cambodia’s rice exports in crisis due to lack of containers and five times higher shipping costs**

*Khmer Times: 01 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

### ៥ខែឆ្នាំនេះ កម្ពុជាទទួលចំណូលជាង១៦៦លានដុល្លារ ពីការនាំចេញអង្ករ ជាង ២៣ម៉ឺនតោន

**In 5 months, Cambodia earn USD 166 million from the over 230,000 MT milled rice export**

*Fresh News: 02 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)






### ទីផ្សារចិនទិញអង្ករកម្ពុជាច្រើនជាងគេ

**China is the biggest market of Cambodian rice**

*Rasmei Kampuchea: 02 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

### ការនាំចេញអង្ករឈានដល់ជាង ២៣ម៉ឺនតោន ក្នុងរយៈពេល៥ខែ

**Cambodia’s milled rice exports exceed 230,000 tonnes in first five months**

*Khmer Times: 02 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)





### បញ្ហាការដឹកជញ្ជូនឡើងថ្លៃ និងកង្វះទូកុងតឺន័រ នៅតែជាកត្តារាំងស្ទះធំ សម្រាប់ការនាំចេញអង្ករកម្ពុជា

**Rising shipping costs and lack of containers remain major barriers to Cambodia's rice exports**

*Cambonomist: 03 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

### អ្នកផលិតស្រូវអង្ករកម្ពុជាចាប់ផ្តើមគិតគូរពីការបញ្ចូលមីក្រូសារជាតិចូលអង្ករ

**Cambodian rice producers start thinking about adding micronutrients to rice**

*Rasmei Kampuchea: 03 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)






### សហព័ន្ធស្រូវអង្ករកម្ពុជាប្តេជ្ញាជំរុញអង្ករ៣ប្រភេទឱ្យកាន់តែមានកេរ្តិ៍ឈ្មោះល្បីនៅលើឆាកអន្តរជាតិ

**Cambodia Rice Federation is committed to promoting three types of rice to become more famous on the international stage**

*Ministry of Information: 04 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

### លោកឧកញ៉ា ហ៊ុន ឡាក់៖ បញ្ហាតម្លៃដឹកជញ្ជូនទៅអឺរ៉ុបធ្វើឲ្យសហព័ន្ធស្រូវអង្ករ ងាកមកជំរុញការនាំចេញនៅក្នុងតំបន់

**Oknha Hun Lak: the issue of shipping prices to Europe push rice federation to boost regional exports**

*RFI: 06 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)






### វិស័យរដ្ឋ និងឯកជន ប្តេជ្ញាជំរុញបច្ចេកទេសថ្មីសម្រាប់ផលិតកម្មស្រូវ

**Public and private sectors vow to promote new technologies for rice production**

*Post Khmer: 08 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

## ព្រះរាជាណាចក្រកម្ពុជាជួយគ្នានៅក្នុងគម្រោង DSR Rice

**Kingdom helps in DSR rice projec**

*Phnom Penh Post: 08 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)





## ចិនបញ្ជាក់ថានឹងនាំចូលផលិតផលកសិកម្មកម្ពុជាបន្ថែមទៀត

**China confirms to import more Cambodian agricultural products**

*Khmer Times: 10 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

## ចក្ខុវិស័យពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាបង្ហាញនូវព័ត៌មានវិជ្ជមាននៃការនាំចេញរបស់សហរដ្ឋអាមេរិកនិងចិន

**Cambodia’s trade outlook brightens on positive US and China export news**

*Khmer Times: 10 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)





## Rice-SDP កម្មវិធីដែលអនុវត្តដោយក្រសួង៤ដើម្បីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

**Rice-SDP, a program implemented by four ministries to boost rice production and rice exports**

*Thmey Thmey: 13 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

## សហព័ន្ធស្រូវអង្ករកម្ពុជា៖ យុទ្ធសាស្រ្តសេដ្ឋកិច្ចដើម្បីលើកកម្ពស់ពាណិជ្ជកម្មអង្ករ

**CRF: Economic strategy to lift milled rice sales**

*Phnom Penh Post: 14 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)



# អន្តរជាតិ ( International )

ឥណ្ឌា ( India )



## ក្រុមហ៊ុននាំចេញអង្ករ Basmati ស្វែងរកការត្រួតពិនិត្យការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតក្នុងដំណាំ ចំពេលមានបទដ្ឋានតឹងរឹងជាងមុនដោយអ្នកទិញបរទេស

**Basmati exporters seek check on use of pesticides in crop amid tougher norms by foreign buyers**

*Hindostantime: 02 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



វៀតណាម ( Vietnam )

## តម្លៃនាំចេញអង្ករធ្លាក់ចុះដែលបង្កការព្រួយបារម្ភដល់សហគ្រាសជាច្រើន

**Export prices of rice fall, causing anxiety to many enterprises**

*Saigon Giai Phong: 02 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

ចិន ( China )



## អ្នកវិទ្យាសាស្ត្រចិនអភិវឌ្ឍពូជស្រូវដែលអាចប្រមូលផលបានច្រើនដងដោយមិនចាំបាច់ដាំជាលើកទីពីរឡើយ

**Chinese scientists develop rice variety that can be harvested multiple times without having to be planted a second time**

*People's Daily Online: 03 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



បង់ក្លាដេស ( Bangladesh )

## ថវិកាឆ្នាំ២០២២៖ អង្ករ២លានតោន នឹងត្រូវបានប្រមូលទិញពីអ្នកផលិតក្នុងស្រុក

**Budget FY22: Two million tons of rice to be procured from local sources**

*Dhaka Tribune: 03 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

វៀតណាម ( Vietnam )

## អត្រាអង្ករវៀតណាមធ្លាក់ចុះ ដោយសារតែអ្នកទិញត្រូវការតម្លៃថោកជាងមុន

**Budget FY22: Two million tons of rice to be procured from local sources**

*Reuters: 04 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



ឥណ្ឌា & ប៉ាគីស្ថាន ( India & Pakistan )

## ឥណ្ឌា និងប៉ាគីស្ថានដណ្តើមយកប័ណ្ណបញ្ជាក់អង្ករ Basmati ទៅកាន់សហភាពអឺរ៉ុប

## India, Pakistan take battle over basmati rice title to EU

*Aljazeera: 07 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

---

វៀតណាម ( Vietnam )

## ក្រុមហ៊ុនវៀតណាមឈ្នះការដេញថ្លៃនាំចេញអង្ករ

## Vietnamese firms win bids for rice exports

*Vietnam Plus: June 07 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



---



ហ្វីលីពីន ( Philippine )

## ហ្វីលីពីនថាអ្នកនាំចូលអង្ករអាចនឹងប្តូរទិសដៅទៅរកអង្ករដែលមានតម្លៃថោកជាងមុន ដែលជាអង្កររបស់ឥណ្ឌា

## Philippines says rice importers may shift to cheaper Indian grains

*Business Times: June 07 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

---

ឥណ្ឌា ( India )

## ឥណ្ឌា លើកពីបញ្ញាតម្លៃអង្ករទិញក្នុងស្រុក ស្របពេលដែលមានការតវ៉ាពីកសិករ

## India raises local rice purchase price amid farmer protests

*Reuters: 09 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)



---



ហ្វីលីពីន & ចិន ( China & Philippines )

## ចិន និងហ្វីលីពីននឹងនៅតែជាប្រទេសនាំចូលអង្ករកំពូលលើពិភពលោក

## China, Philippines to remain world’s top rice importers

*Rapple: 11 June 2021* ចុចទីនេះ ដើម្បីអាន ( Click here to read)

ប៉ាគីស្ថាន (Pakistan)



## រុស្ស៊ីអនុញ្ញាតឱ្យនាំចូលអង្ករពីប៉ាគីស្ថាន

**Russia allows rice import from Pakistan**

*Tribune: 11 June 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)



ឥណ្ឌា & ប៉ាគីស្ថាន (India & Pakistan)

## អ្នកនាំចេញប៉ាគីស្ថាននិងឥណ្ឌាយល់ព្រមចែករំលែកភាពជាម្ចាស់លើអង្ករBasmati

**Pakistani, Indian exporters agree to share Basmati rice ownership**

*Tribune: 13 Jun 2021*

ចុចទីនេះ ដើម្បីអាន (Click here to read)

## ព្រឹត្តិការណ៍/សកម្មភាព

Event/ Activity

## កិច្ចប្រជុំស្តីពី "ការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣"




នាព្រឹកថ្ងៃសុក្រ ២កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ **ឧកញ៉ា សុខ សារ៉ែន** ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា និងលោក **លន់ យ៉េង** អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា បានចូលរួមក្នុងកិច្ចពិភាក្សា នៅក្នុងកម្មវិធីកិច្ចប្រជុំតាមរយៈវីដេអូ ស្តីអំពី "ការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣" ដែលរៀបចំឡើងដោយក្រសួងការបរទេសកម្ពុជា។

ការដាក់ចេញនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច មានសារៈសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារការទូត។ គោលបំណងនៃយុទ្ធសាស្ត្រនេះរួមមាន៖ ជំរុញពាណិជ្ជកម្មអន្តរជាតិ ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងការជំរុញការលើកស្ទួយវិស័យទេសចរណ៍ និងវប្បធម៌របស់កម្ពុជា។

សហព័ន្ធស្រូវអង្ករកម្ពុជា ជឿជាក់ និងយល់ស្របតាមយុទ្ធសាស្ត្រគន្លឹះដែលដាក់ចេញក្នុងការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចកម្ពុជា ដែលក្នុងនោះបានលើកឡើង អំពីការលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ តាមរយៈការជំរុញ និងធ្វើពិពិធកម្មទាំងផលិតផលនាំចេញ និងទីផ្សារនាំចេញ ការស្វែងរក និងទាញយកកាលានុវត្តភាពពីទីផ្សារថ្មីៗ សម្រាប់ផលិតផល និងសេវាកម្មកម្ពុជា និងការពង្រឹងកិច្ចសហប្រតិបត្តិការ







និងភាពជាដៃគូសេដ្ឋកិច្ចអន្តរជាតិ ដោយផ្តោតលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី។ បន្ថែមពីនោះ យុទ្ធសាស្ត្រគន្លឹះមួយទៀតរបស់យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច គឺយុទ្ធសាស្ត្រផ្សព្វផ្សាយកិត្តិនាម ដែលសហព័ន្ធកម្ពុជាជឿជាក់ថា  ពិតជាសមស្រប នឹងយុទ្ធសាស្ត្ររបស់សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការផ្សព្វផ្សាយកេរ្តិ៍ឈ្មោះអង្ករកម្ពុជាប្រកបដោយគុណភាព នៅលើទីផ្សារអន្តរជាតិ ដើម្បីពង្រីកទីផ្សារនាំចេញកម្ពុជា សម្រេចឱ្យបាននូវទិសដៅនាំចេញអង្ករ១លានតោនរបស់រាជរដ្ឋាភិបាលកម្ពុជា។

កិច្ចប្រជុំក៏បានលើកឡើងអំពីតួនាទីរបស់វិស័យឯកជន ដែលជាតួអង្គសំខាន់មិនអាចខ្វះបាននៅក្នុងយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ ក្នុងនោះ ឧកញ៉ា សុង សារ៉ន បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់របស់ក្រសួងការបរទេស និងស្ថានតំណាងកម្ពុជានៅបរទេស ក្នុងការរៀបចំឱ្យមាននូវកិច្ចប្រជុំនាថ្ងៃនេះ ដែលមានការលើកឡើងនូវគំនិតយោបល់ និងសកម្មភាពការងារយ៉ាងច្រើន ក្នុងការធ្វើយ៉ាងណា ជំរុញឱ្យការងារការទុតសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាព ក្នុងនោះផងដែរ ឧកញ៉ាប្រធានបានសំណូមពរបន្ថែមឱ្យសហព័ន្ធស្រូវអង្ករជាពិសេសគឺពាណិជ្ជករអង្ករ អាចចូលរួមក្នុងកម្មវិធីចំណងមិត្តភាពនានា (Networking event) តួយ៉ាងដូចជាការអញ្ជើញស្ថានទូតក្នុងកម្មវិធីទទួលទានអាហារខ្មែរ ដើម្បីបង្កើនទំនាក់ទំនងល្អ និងមានការផ្លាស់ប្តូរយោបល់ពីតួអង្គដែលអនុវត្តផ្ទាល់តែម្តង ជាពិសេសគឺស្នើឱ្យបន្តជំរុញអង្ករកម្ពុជា ម្លិះអង្ករ នៅក្នុងមីនុយ តាមភោជនីយដ្ឋានខ្មែរនានា នៅបរទេស ដែលគឺជាយុទ្ធសាស្ត្រមួយដ៏ល្អក្នុងការផ្សព្វផ្សាយអំពីអង្ករខ្មែរដោយផ្ទាល់តាមរយៈម្ហូបអាហារ។

លោក លន់ យ៉េង អគ្គលេខាធិការ ស.អ.ក ក៏បានចូលរួមបង្ហាញចំណាប់អារម្មណ៍ខ្ពស់ និងចូលរួមឆ្លើយតបអំពីកិច្ចការងារដែលសហព័ន្ធស្រូវអង្ករកម្ពុជា បាននិងកំពុងអនុវត្តជាមួយវិស័យសាធារណៈ និងលើកអំពីបញ្ហាប្រឈមនៅក្នុងការអនុវត្តការងារផងដែរ ដែលជាសំខាន់គឺផ្តោតលើការផ្សព្វផ្សាយព័ត៌មានជាក់លាក់អំពីអង្ករកម្ពុជារបស់ស្ថានតំណាងកម្ពុជា នៅបរទេសទៅកាន់ភ្ញៀវ។ លោក លន់ យ៉េង ក៏បានបង្ហាញការចាប់អារម្មណ៍ទៅលើសៀវភៅ The Taste of Angkor របស់ក្រសួងការបរទេស ដែលមានបញ្ចូលនូវអង្ករម្លិះអង្កររបស់កម្ពុជា ដែលជាប់ជ័យលាភីជាអង្ករល្អបំផុតលើពិភពលោក៤ឆ្នាំ ហើយលោកស្នើឱ្យសូមបន្ថែមនូវ ទៅដល់ក្រសួងការបរទេសឱ្យជួយបន្ថែមព័ត៌មានអំពីអង្ករខ្មែរឱ្យកាន់តែបានទូលាយជាងនេះ នៅក្នុងការបោះពុម្ពលើកក្រោយ ឬនៅតាមវេបសាយផងដែរ។ លោកក៏សូមឱ្យមាននូវការគាំទ្រក្នុងរូបភាពជាកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងយកចិត្តទុកដាក់ លើការងារផ្សព្វផ្សាយអំពីអង្ករខ្មែរ តាមរយៈការតាំងពិព័ណ៌ និងកម្មវិធីអន្តរជាតិនានា និងតាមរយៈឧបករណ៍ផ្សព្វផ្សាយដូចជាខិត្តប័ណ្ណ សៀវភៅ ជាដើម ដែលអាចលើកកម្ពស់កិត្តិនាមកម្ពុជានៅលើឆាកអន្តរជាតិ សមស្របតាមយុទ្ធសាស្ត្រការងារការទូតសេដ្ឋកិច្ចកម្ពុជាផងដែរ។

ជាការឆ្លើយតប ក្រសួងការបរទេសបានទទួលយកសំណូមពររបស់តំណាងស្ថាប័ន សមាគម សហព័ន្ធនានា ក៏ដូចជាសហព័ន្ធស្រូវអង្ករកម្ពុជាផងដែរ ហើយជាការងារបន្ទាប់ នឹងមានការសហការគ្នាក្នុងរូបភាពផ្សេងៗ និងការចែករំលែកព័ត៌មាននៅក្នុង Telegram Group ដែលបង្កើតដោយក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច។

លោកអ្នកអាចទាញយកឯកសារយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣៖ [https://drive.google.com/drive/u/0/folders/1g-HhwjWweUyCMnKdwAjmgS_S0czKJKTZ](https://drive.google.com/drive/u/0/folders/1g-HhwjWweUyCMnKdwAjmgS_S0czKJKTZ)

Click here for English article: [Meeting on “Implementation of Economic Diplomacy Strategy 2021-2023”]

# តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
# (Paddy price & FOB Price)

## តម្លៃស្រូវ នៅវាលស្រែ
### ដែលកំពុងប្រមូលផល តាមបណ្តាខេត្តមួយចំនួន

ថ្ងៃចន្ទ ទី១៤ ខែមិថុនា ឆ្នាំ២០២១

គិតជារៀល/គីឡូក្រាម

| ខេត្ត | ស្រុក | សែនក្រអូប | អូអឹម ៥៤៥១ | អ៊ីអ៊ែរ ៨៥ | ផ្សេងៗ |
|---|---|---|---|---|---|
| កំពង់ធំ | ស្ទោង | | 900-920 | | |
| | សន្ទុក | | 900-920 | | |
| បាត់ដំបង | បាណន់ | 1070-1120 | 920-930 | 920-930 | 990-1020 |
| កំពង់ឆ្នាំង | កំពង់ត្រឡាច | | 860-880 | 860-880 | |
| ព្រៃវែង | ពារាំង | | 890-970 | | |
| | ស្វាយអន្ទរ | | 890-970 | | |
| | កំពង់ត្របែក | | 920-950 | | |
| តាកែវ | អង្គរបុរី | | 900-920 | | |

**ប្រភពទិន្នន័យ**

- សហគមន៍កសិកម្មនៅតាមបណ្តាខេត្ត
  ១. ស្រុកបាណន់ ខេត្តបាត់ដំបង (012 824 665, 088 5764 011)
  ២. ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង (089 509 232)
  ៣. ស្រុកពារាំង ខេត្តព្រៃវែង (097 4968 066)
  ៤. ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង (012 193 4283)
  ៥. ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (097 907 0328)
- Agribee Cambodia PLC (096 77 00 111)

## សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

**តម្លៃអង្ករនាំចេញ FOB Price**
as of 18 May 2021

| Rice Varieties | Rice Standard (Price USD/ MT) 5% |
|---|---|
| Jasmine Rice (Malys Angkor) | 800 |
| Standard Fragrant Rice_SKO | 770 |
| White Rice_Premium (Soft cooking) | 550 |
| Parboiled Rice | 580 |
| Organic Parboiled Rice (Premium Quality) | 990 |
| Organic White Rice (Premium Quality) | 920 |
| Organic Jasmine (Malys Angkor) | 1380 |
| Organic Brown Jasmine (Premium Quality) | 1350 |

**Source :** Cambodian Exporters and Millers
**Note:** Price Fluctuation : +/- 2%


**សហព័ន្ធស្រូវអង្ករកម្ពុជា** (Cambodia Rice Federation)

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
*លោកឧកញ៉ា ហ៊ុន ឡាក់ (Oknha Hun Lak)*

**ប្រធានសហព័ន្ធ (President)**
*លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)*

**អគ្គលេខាធិការ (Secretary General)**
*លោក លន់ យ៉េង (Mr. Lun Yeng)*

**រៀបរៀងដោយ (Prepared by)**
*កញ្ញា សន ធវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*

+855 23 559 8999
info@crf.org.kh
www.crf.org.kh
www.facebook.com/cambodiaricefederation
twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation